# ប្រវត្តិដែនដីកម្ពុជាក្រោម

កម្ពុជាក្រោមជាអតីតទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅខាងកើតឆៀងខាងត្បូងនៃព្រះរាជាណាចក្រកម្ពុជា ។ បច្ចុប្បន្ន ជាចំណែកមួយនៃទឹកដីសាធារណរដ្ឋសង្គមនិយមវៀតណាមប៉ែកខាងត្បូង (**South Vietnam**) ។ កម្ពុជាក្រោមត្រូវអាណានិគមបារាំងកាត់ផ្តាច់ពីកម្ពុជាផ្តល់ទៅឱ្យអាជ្ញាធរវៀតណាមធ្វើអាណានិគមបន្តរហូតដល់សព្វថ្ងៃ ក្រោមច្បាប់អាណានិគមបារាំងលេខ៤៩-៧៣៣ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ នៅទីក្រុង **Toulon** នៃប្រទេសបារាំង ។

កាលពីសម័យដើម ទឹកដីកម្ពុជាក្រោមគេហៅថាកម្ពុជាទឹកលិច ឬកម្ពុជាក្រោម(កម្ពុជាប៉ែកខាងក្រោម) ហើយ គេអាចហៅបានម្យ៉ាងទៀតថា ដែនដីសណ្តទន្លេមេគង្គ (**Mekong Delta**) ។ នៅសម័យអាណានិគមបារាំងត្រួតត្រា ឥណ្ឌូចិន ទឹកដីកម្ពុជាក្រោមត្រូវបានបារាំងហៅថា **Basse Cochinchine** (កូសាំងស៊ីនក្រោម) ។

ចំពោះផ្ទៃដី និងចំនួនប្រជារាស្ត្រខ្មែរដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោមសព្វថ្ងៃ នៅមានបញ្ហាស្មុគស្មាញណាស់ ពីព្រោះពុំមានវិជ្ជាស្ថានជាតិណាមួយបានធ្វើជំរឿនឬកំណត់ឱ្យបានច្បាស់លាស់ទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ យើងបានធ្វើការសិក្សាស្រាវជ្រាវតាមឯកសារដើមសម័យអាណានិគមបារាំងត្រួតត្រាឥណ្ឌូចិន បានបង្ហាញឱ្យឃើញថាទឹកដី កម្ពុជាក្រោមមានទំហំផ្ទៃដី៦៨.៩៦៥ $Km^2$ ។ តួលេខនេះ គិតតាមឯកសារបារាំងក្នុងឆ្នាំ១៩៤៥ ព្រោះនៅពេលនោះ អាណានិគមបារាំងបានបែងចែកទឹកដីនៅឥណ្ឌូចិនចំនួន៥ប្រទេសដើម្បីងាយស្រួលក្នុងការត្រួតត្រាគឺ:

១-ប្រទេសយួន មានផ្ទៃដី១០៣.000$Km^2$ ។

២- ប្រទេសចម្ប៉ា មានផ្ទៃដី១៤៨.000 $Km^2$ ។

៣- ប្រទេសលាវ មានផ្ទៃដី២៣៦.000 $Km^2$ ។

៤- ប្រទេសកម្ពុជា មានផ្ទៃដី១៨៥.000 $Km^2$ ។

៥- កម្ពុជាក្រោម មានផ្ទៃដី៦៥.000 $Km^2$ ។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាប្រកាសជាផ្លូវការថាមានផ្ទៃដី១៨១.០៣៥ $Km^2$ ។ ដូច្នេះ ទឹកដីកម្ពុជាក្រោមត្រូវកើនបន្ថែមចំនួន៣.៩៦៥ $Km^2$ បូកនឹង៦៥.000 $Km^2$ ត្រូវជា៦៨.៩៦៥ $Km^2$ (185.000 $Km^2$ – 181.035 $Km^2$ + 65.000 $Km^2$ =68.965 $Km^2$) ។ រីឯចំនួនប្រជារាស្ត្រខ្មែរនៅកម្ពុជាក្រោមវិញ យើងបានធ្វើជំរឿនដោយផ្អែកទៅលើឯកសារចំនួន៥ដូចខាងក្រោម:

ទី១ តួលេខសម្រង់ស្ថិតិខ្មែរកម្ពុជាក្រោមរបស់រដ្ឋាភិបាលអាណានិគមបារាំងនៅក្នុងឆ្នាំ១៩២៤មាន៨0.000 (ប្រាំបីម៉ឺន)នាក់ ។

ទី២ តួលេខស្រង់ស្ថិតិរបស់រណសិរ្សរំដោះកម្ពុជាក្រោមនៅឆ្នាំ១៩៦៨មាន ៤.០៤៧.៥០០(បួនលានបួនម៉ឺនប្រាំពីរពាន់ប្រាំរយ)នាក់ ។

ទី៣ សេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់លោកប្រធានាធិបតីវៀតណាមង្វៀន វ៉ានធីវ នៅទីក្រុងព្រែកឫស្សីក្នុងឆ្នាំ ១៩៦៩ ថាប្រជារាស្ត្រខ្មែរកម្ពុជាក្រោមមានប្រមាណជាង៤.០០០.០០០(បួនលាន)នាក់ ។

ទី៤ ឯកសារសមាគមខ្មែរកម្ពុជាក្រោមនៅប្រទេសបារាំងឆ្នាំ១៩៦៩បានសរសេរថាខ្មែរនៅកម្ពុជាក្រោមមានចំនួន ៤.៥០០.០០០(បួនលានប្រាំសែន)នាក់ ។

ទី៥ តួលេខបូកសរុបប្រជារាស្ត្រខ្មែររបស់រដ្ឋាភិបាលខ្មែរនៅសាលសន្និសីទចតុម្មុខក្នុងឆ្នាំ១៩៧០ ឃើញប្រជារាស្ត្រខ្មែរនៅកម្ពុជាក្រោមមានចំនួន៤.៥០០.០០០នាក់។

រីឯនៅកម្ពុជានាពេលនោះពលរដ្ឋខ្មែរមានចំនួនជិត៧.០០០.០០០ (ប្រាំពីរលាន)នាក់ ។

ដូច្នេះ បានសេចក្តីថា សព្វថ្ងៃនេះ ពុំមានឯកសារណាមួយ ឬប្រភពណាមួយបានធ្វើជំរឿនស្ថិតិប្រជារាស្ត្រខ្មែរកម្ពុជាក្រោមឱ្យបានច្បាស់លាស់ពិតប្រាកដទេ ។ ប៉ុន្តែ បើផ្អែកតាមតួលេខខាងលើដែលអាចយកជាការបាននោះ គិតមកដល់ ដំណាច់ឆ្នាំ២០០៤ឃើញថា នៅកម្ពុជាក្រោម មានប្រជារាស្ត្រខ្មែររស់នៅប្រមាណជាង១២លាននាក់ ។ របៀបធ្វើជំរឿន ប្រជាជន (Recencement de la Population) គឺគិតកំណើនប្រជារាស្ត្រក្នុង២០ឆ្នាំម្តង បានសេចក្តីថា២០ឆ្នាំក្រោយមក ឆ្នាំ ១៩២៤-១៩៤៤មាន១.៦០០.០០០នាក់ (៨០.០០០ × ២០ = ១.៦០០.០០០); ២០ឆ្នាំក្រោយមកទៀត ឆ្នាំ១៩៤៤-១៩៦៤មាន ៣.២០០.០០០នាក់(១.៦០០.០០០ × ២០ = ៣.២០០.០០០នាក់); ២០ឆ្នាំក្រោយមកទៀត ឆ្នាំ១៩៦៤-១៩៨៤ មាន ៦.៤០០.០០០នាក់(១.៦០០.០០០ × ២០ = ៦.៤០០.០០០នាក់) ២០ឆ្នាំក្រោយមកទៀត ឆ្នាំ១៩៨៤-២០០៤ មាន ១២.៨០០.០០០(ដប់ពីរលានប្រាំបីសែន)នាក់ (៦.៤០០.០០០ × ២០ = ១២.៨០០.០០០នាក់)

ចំណែកឯកសារទាំងប៉ុន្មានក្រៅពីនេះ ពេលធ្វើជំរឿនឃើញថា ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម មានរហូតពី១៤ទៅ ១៥លាននាក់ឯណោះ ។

តាមឯកសាររបស់រណសិរ្សរំដោះខ្មែរកម្ពុជាក្រោម បានធ្វើសម្រង់ស្ថិតិចំនួនប្រជារាស្ត្រខ្មែរកម្ពុជា ក្រោម ដែលកំពុងរស់នៅតាមបណ្តាខេត្ត-ក្រុងនិមួយៗទូទាំង២១ខេត្ត-ក្រុងក្នុងឆ្នាំ១៩៦៨មានចំនួន៤.០៤៧.៥០០នាក់ ហើយបើធ្វើជំរឿនប្រជារាស្ត្រខ្មែរទាំងនោះ រហូតមកដល់ បច្ចុប្បន្ន (ទី០១ មករា ២០០៥)ឃើញថាមានចំនួន ១៤.៥៧១.០០០នាក់ ដោយរស់នៅតាមខេត្តនិមួយៗដូចតទៅ:

១- ខេត្តព្រះត្រពាំង មានប្រជារាស្ត្រខ្មែររស់នៅចំនួន ២.៨៨៥.០០០នាក់

២- ខេត្តឃ្លាំង មានប្រជារាស្ត្រខ្មែររស់នៅចំនួន ២.៧០៣.០០០ នាក់

៣- ខេត្តមាត់ជ្រូក មានប្រជារាស្ត្រខ្មែររស់នៅចំនួន ២.៥២២.០០០នាក់

៤- ខេត្តក្រមួន ស មានប្រជារាស្ត្រខ្មែររស់នៅចំនួន ២.៥២១.០០០ នាក់

៥- ខេត្តពលលាវ មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៧២៥.០០០នាក់

៦- ខេត្តទឹកខ្មៅ មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៧២០.៥០០នាក់

៧- ខេត្តពាម មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៥៤០.០០០នាក់

៨- ខេត្តព្រែកឫស្សី មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៣៦០.០០០នាក់
៩- ខេត្តលង់ ហោរ មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៣៦០.៤០០នាក់
១០- ខេត្តបារ៉ាជូ មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៣៦១.០០០នាក់
១១- ខេត្តរោងដំរី មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៣៦២.០០០នាក់
១២- ទីក្រុងព្រៃនគរ មានប្រជារាស្ត្រខ្មែររស់នៅចំនួន ២៨៨.៥០០នាក់
១៣- ខេត្តទួលតាមោក មានប្រជារាស្ត្រខ្មែររស់នៅចំនួន ១០៨.០០០នាក់
១៤- ខេត្តផ្សារដែក មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៣៦.៣០០នាក់
១៥- ខេត្តចង្វាត្រពាំង មានប្រជារាស្ត្រខ្មែររស់នៅចំនួន ២១.៦០០នាក់
១៦- ខេត្តព្រះសួគ៌ា មានប្រជារាស្ត្រខ្មែររស់នៅចំនួន ១២.៦០០នាក់
១៧- ខេត្តមេស មានប្រជារាស្ត្រខ្មែររស់នៅចំនួន ១១.៤០០នាក់
១៨- ខេត្តកោះគង មានប្រជារាស្ត្រខ្មែររស់នៅចំនួន ១១.១០០នាក់
១៩- ខេត្តកំពង់ឫស្សី មានប្រជារាស្ត្រខ្មែររស់នៅចំនួន ១១.៥២០នាក់
២០- ខេត្តឈ្មោះថ្មី មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៥.៤០០នាក់
២១- ខេត្តអូរកាប់ មានប្រជារាស្ត្រខ្មែររស់នៅចំនួន ៤.៦៨០នាក់ ។

សរុបៈ *១៤.៥៧១.០០០*នាក់

(ដប់បួនលាន់ ប្រាំសែន ប្រាំពីរម៉ឺនមួយពាន់នាក់)

ដូច្នេះយើងកំណត់យកចំនួនដែលតិចជាងគេនោះ គឺតាមឯកសារសម្រង់ស្ថិតិរបស់អាណានិគមបារាំងក្នុងឆ្នាំ១៩២៤ គិតមកដល់បច្ចុប្បន្ន(ថ្ងៃ០១ មករា ២០០៥) មានចំនួន១២.៨០០.០០០នាក់) ។

ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម៩៥%ជាកសិករ, ៣%ជាអ្នករដ្ឋការ, ២%ជាអ្នកជំនួញ ៨៥%មិនចេះអក្សរ ស្ត្រី៩៩%។ តំបន់ដែលប្រជារាស្ត្រខ្មែរ រស់នៅច្រើនជាងគេគឺខេត្តព្រះត្រពាំង(**Tra Vinh**), ខេត្តឃ្លាំង(**Soc Trang**), ពលលាវ(**Bac Lieu**) មាត់ជ្រូក(**Chau Doc**), ក្រមួនស (**Kien Giang**), ពាម(**Ha Tien**), ព្រែកឫស្សី(**Can Tho**) និងខេត្តទឹកខ្មៅ(**Ca Mau**)។ ប្រជារាស្ត្រ ខ្មែរកម្ពុជាក្រោម៨៥%មិនចេះអក្សរ ។

## អំពីសង្គមសាស្ត្រ:

ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ជាជាតិសាសន៍ស្លូតត្រង់ គោរពជំនឿព្រះពុទ្ធសាសនា៩៩% ។ ការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម មានទំនៀមទំលាប់ វប្បធម៌ ប្រពៃណីដូចប្រជាពលរដ្ឋខ្មែរនៅកម្ពុជា១០០% គ្រាន់តែខុសគ្នាត្រង់សំលៀកបំពាក់និងសំនៀងភាសាបន្តិចបន្តួចតែប៉ុណ្ណោះ ។

នៅកម្ពុជាក្រោម មានវត្តព្រះពុទ្ធសាសនាខ្មែរជាង៥៦០វត្ត មានព្រះសង្ឃគង់នៅជាង២០.០០០អង្គ ។ វត្តព្រះពុទ្ធ សាសនានិងព្រះសង្ឃជាព្រលឹងនៃជាតិខ្មែរកម្ពុជាក្រោម ។ វត្តជាទីប្រជុំជន ជាកន្លែងអប់រំសីលធម៌ ជាកន្លែងបណ្តុះ បណ្តាលធនធានមនុស្ស ជាកន្លែងផ្តល់ពត៌មាន ផ្សព្វផ្សាយពត៌មាន ។ល។ ការទាក់ទងគ្នាក្នុងសង្គមខ្មែរកម្ពុជាក្រោម គឺជាភាសាខ្មែរនិងអក្សរខ្មែរ ។ រីឯការប្រើប្រាស់ជាផ្លូវការ គឺភាសានិងអក្សរសាស្ត្រវៀតណាម ។

## អំពីវប្បធម៌:

មជ្ឈមណ្ឌលផ្សាយវប្បធម៌សំខាន់បំផុតនៅកម្ពុជាក្រោម គឺស្ថិតនៅក្នុងវត្តព្រះពុទ្ធសាសនាទាំងជាង៥៦០វត្ត ។ វត្តព្រះពុទ្ធសាសនាទាំងនេះហើយដែលជាមូលដ្ឋានដ៏រឹងមាំក្នុងការការពារពូជសាសន៍ វប្បធម៌ អក្សរសាស្ត្រ ភាសាសាស្ត្រ និងទំនៀមទម្លាប់ ប្រពៃណីខ្មែរនៅកម្ពុជាក្រោមឱ្យរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។

ការសិក្សារៀនសូត្រ វប្បធម៌ អក្សរសាស្ត្រខ្មែរ គឺមានតែក្នុងវត្តអារាមប៉ុណ្ណោះ ។ អាជ្ញាធរអាណានិគមវៀតណាមមិនអនុញ្ញាតឱ្យមានសាលារៀនភាសាខ្មែរនៅតាមភូមិស្រុកឡើយ ។

ពលរដ្ឋខ្មែរកម្ពុជាក្រោម គោរពទំនៀមទំលាប់ វប្បធម៌របស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនបំផុត ដូចជាពិធីអាពាហ៍ពិពាហ៍ បុណ្យបូជាសព បុណ្យក្នុងព្រះពុទ្ធសាសនា បុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ អកអំបុក សំពះព្រះខែជាដើម ។

រីឯសំលៀកបំពាក់មានការប្រែប្រួលច្រើន ដោយសារអាណានិគមវៀតណាមបានបង្ខំឱ្យប្រជារាស្ត្រខ្មែរកម្ពុជាក្រោមស្លៀកពាក់តាមបែបប្រពៃណីវៀតណាម ។ ដូចនេះ ការស្លៀកពាក់តាមបែបប្រពៃណីខ្មែរមានតិចតួចបំផុត ស្ទើរតែ គ្មានតែម្តង ។

## អំពីសេដ្ឋកិច្ច:

សេដ្ឋកិច្ចសំខាន់បំផុតនៅកម្ពុជាក្រោមគឺកសិកម្ម ។ ប្រជារាស្ត្រកម្ពុជាក្រោម៩៥%ជាកសិករ ប៉ុន្តែពុំបានធ្វើឱ្យជីវភាពរបស់ពួកគាត់ធូរធារឡើយ ដោយសារថា កសិផលទាំងនោះត្រូវឋិតនៅក្រោមការត្រួតត្រារបស់អាណានិគមវៀតណាមយ៉ាងតឹងរ៉ឹងបំផុត ។

នៅឆ្នាំ១៩៧៥ ពួកកុម្មុយនីស្តវៀតណាមបានត្រួតត្រាអំណាចនៅលើទឹកដីវៀតណាមទាំងមូល ។ ចាប់ពីពេលនោះមក អាជ្ញាធរអាណានិគមវៀតណាម បានរឹបអូសយកដីស្រែរបស់ប្រជាពលរដ្ឋខ្មែរទាំងស្រុង មកទុកជាសម្បត្តិ រួមបង្កើតទៅជាសហករណ៍ ។ ទន្ទឹមនឹងនោះ រដ្ឋអំណាចអាណានិគមវៀតណាមបានចាប់ផ្តើមកេណ្ឌមនុស្សជីកព្រែកខ្វាត់ខ្វែងដែលពួកអាណានិគមយួនហៅថា នយោបាយទឹកដើម្បីស្រោចស្រពដំណាំកសិកម្ម ។ ផ្ទុយទៅវិញ ក្រោយពីជីកព្រែករួច អាជ្ញាធរអាណានិគមវៀតណាមបែរជាបញ្ជូនប្រជាជនយួនទៅរស់នៅតាមភ្លឺព្រែកទាំងនោះ ហើយក៏ចាប់ផ្តើមចែកដីស្រែជាថ្មីឡើងវិញ ។ ពេលនោះហើយដែលប្រជាពលរដ្ឋខ្មែរត្រូវធ្លាក់ខ្លួនក្រីក្រវេទនាជាទីបំផុត ព្រោះពុំមានដីស្រែចំការ និងមុខរបរពិតប្រាកដ ហើយក៏បង្ខំចិត្តដើរស៊ីឈ្នួលប្រជាជនយួនទៅតាមតំបន់ផ្សេងៗ ។ រីឯជនជាតិយួនវិញគេបានប្រជ្រៀតចូលរស់នៅក្នុងតំបន់ខ្មែរ និងមានដីស្រែចំការយ៉ាងច្រើនក្រាស់ក្រែលថែមទៀត ។

បច្ចុប្បន្ន នៅពេលប្រជារាស្ត្រខ្មែរធ្លាក់ខ្លួនក្រីក្រ ពួកជនជាតិយួន( មិនដឹងបានប្រាក់ពីណា) បានដើរទិញដីស្រែចំការ របស់ប្រជាពលរដ្ឋខ្មែរដែលនៅសេសសល់បន្តិចបន្តួចជាបង្ហើយចុងក្រោយ ។ ដូច្នេះ ប្រជាពលរដ្ឋខ្មែរត្រូវក្លាយជាទាសករ នៅលើទឹកដីកំណើតរបស់ខ្លួនយ៉ាងវេទនាបំផុត ។ ចំណែកឯក្រុមហ៊ុន សិប្បកម្ម រោងចក្រ ពិសេសរោងចក្រកាត់ដេរ សំលៀកបំពាក់ អាជ្ញាធរអាណានិគមវៀតណាម មិនបានពង្រីកទៅដល់តំបន់ប្រជារាស្ត្រខ្មែររស់នៅឡើយ ។

## អំពីប្រវត្តិសាស្ត្រ:

កម្ពុជាក្រោមជាទឹកដីដែលមានចំណាស់ជាងគេបង្អស់នៅភូមិភាគអាស៊ីអគ្នេយ៍ ។ ប្រជារាស្ត្រខ្មែរបានចាប់ឆ្ការព្រៃ ទន្រ្ទានកាន់កាប់តាំងលំនៅៗលើទឹកដីនេះមុនគេបង្អស់ ។ កាលដើមឡើយ ទឹកដីកម្ពុជាក្រោមជាកម្មសិទ្ធិស្របច្បាប់របស់ ព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រងដោយព្រះរាជាខ្មែរគ្រប់ជំនាន់ ។ លុះដល់ឆ្នាំ១៨៥៥ ពេលដែលបារាំងចូលមក ដល់កម្ពុជាក្រោម យកទឹកដីនេះដាក់ក្រោមការត្រួតត្រារបស់ខ្លួនជារៀងរហូត ។ មកដល់ឆ្នាំ១៩៤៩ អាណានិគមបារាំងក៏ ធ្វើច្បាប់លេខ៤៩-៧៣៣ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ ប្រគល់ឱ្យអាជ្ញាធរវៀតណាមធ្វើអាណានិគមជាបន្តរហូតដល់ សព្វថ្ងៃ ។

ក្រុមភូមិវិទូ និងប្រវត្តិវិទូក្នុងសកលលោក ដែលជាអ្នកឯកទេសខាងប្រទេសនៅអាស៊ីអគ្នេយ៍ តែងតែបានសរសេរ អំពីប្រវត្តិសាស្ត្រដែនដីកម្ពុជាក្រោមយ៉ាងក្បោះក្បាយ ព្រមទាំងបានបញ្ចេញយោបល់ថា *"កម្ពុជាក្រោម ជាបុព្វសិទ្ធិរបស់ ខ្មែរ ប្រជារាស្ត្រខ្មែរមានសិទ្ធិបរិបូរណ៍ក្នុងការទាមទារទឹកដីកម្ពុជាក្រោមមកវិញ..."* ។ សូម្បីតែអ្នកប្រាជ្ញជនជាតិវៀតណាមឈ្មោះត្រឹន ហ្វាយឌឹក(Trân Hoai Duc) ដែលបានសរសេរសៀវភៅឈ្មោះ *"យ៉ាឌីញទុងជី"* ក្នុងឆ្នាំ១៨៣០ ក៏បានទទួលស្គាល់ថាកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរដែរ ។ ក្រៅពីនេះ នៅមានភស្តុតាងជាច្រើនទៀត ដូចជាវត្តព្រះពុទ្ធសា សនាខ្មែរជាង៥៦០វត្ត សិលាចារិក ប្រាសាទសិលា និងសិល្បៈនានាមានទេពកោសល្យខ្ពស់ដូចរចនាបថអង្គរវត្ត មាននៅ រាយប៉ាយពាសពេញលើទឹកដីកម្ពុជាក្រោម ។ ប៉ុន្តែបច្ចុប្បន្នឈ្មោះភូមិ ឃុំ ស្រុក ខេត្តជាភាសាខ្មែរ ត្រូវអាជ្ញាធរអាណានិគម វៀតណាម ប្តូរមកជាសំនៀងភាសាវៀតណាមជាច្រើនលើកច្រើនសាទាំងស្រុងតែម្តង ។ សកម្មភាពកែប្រែភូមិសាស្ត្រ នេះ អាជ្ញាធរអាណានិគមវៀតណាម បានធ្វើឡើងនៅគ្រប់សម័យកាល គ្រប់របបនយោបាយ ដើម្បីបំភ័ន្តសាធារណមតិ ជាតិ និងអន្តរជាតិ ។

ក្រៅអំពីភស្តុតាងបូរាណវត្ថុវិទ្យានេះ មានផែនទីពីសម័យដើមក៏បានបញ្ជាក់ច្បាស់ផងដែរគឺ:

*១- ផែនទីឥណ្ឌូចិននៅសតវត្សទី៧ និងទី៨:*

តាមផែនទីទាំងនេះ យើងបានមើលឃើញយ៉ាងច្បាស់លាស់បំផុតអំពីទីតាំងរបស់ប្រទេសកម្ពុជា ដោយនិយាយ ធៀបប្រៀបទៅនឹងប្រទេសជិតខាងរបស់ខ្លួន គឺប្រទេសសៀម ប្រទេសលាវ ប្រទេសអណ្ណាម

និងនគរចំប៉ា ។នៅក្នុងសៀវភៅ"ប្រវត្តិសាស្ត្រកម្ពុជា" ត្រង់ទំព័រទី១១(Histoire du Cambodge, Madrolle) លោកម៉ាដ្រូលបានសរសេរថា ផ្នែក ដែនដីរួមនៅក្នុងព្រំដែនព្រះរាជាណាចក្រកម្ពុជានេះ ហើយគឺជាផ្នែកទាំងស្រុងមួយនៃបូរណភាពទឹកដីរបស់ខ្មែរ(គឺជារបស់ ខ្មែរទាំងស្រុង) ។

*២- ផែនទីឥណ្ឌូចិនមួយទៀត គូរនៅឆ្នាំ១៥៩៣:*

ចំនួន៧០០ឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៥៩៣ ផែនទីឥណ្ឌូចិនមួយទៀតដែលគេបានគូរជាថ្មីឥតមានកែប្រែគំនូស (Traces)របស់ផែនទីគូរនាសតវត្សទី៧សោះនោះ ។ កូសាំងស៊ីនក្រោម ដែលកើតឡើងដោយដីដុះ និងល្បប់ទន្លេមេគង្គ ជាទីតាំងបន្តនៃព្រះរាជាណាចក្រកម្ពុជានៅលើដីដុះធម្មជាតិ(Contiuation Geologique)នៃប្រទេសគោកធ្លក ។

*៣- ផែនទីឥណ្ឌូចិនគូរនៅឆ្នាំ១៦៣៨:*

ចំនួន៣០ឆ្នាំក្រោយមកទៀត គេបានគូរផែនទីមួយទៀតដែលបានបង្ហាញយ៉ាងច្បាស់ថា "កូសាំងស៊ីនបច្ចុប្បន្ន ដែលជាដែនដីប៉ែកសមុទ្ររបស់ប្រទេសកម្ពុជា នៅតែជាដែនដីទាំងមូលរួមក្នុងប្រទេសកម្ពុជា ប្រទេសនេះ(កម្ពុជា) លាត សន្ធឹងតែម្នាក់ឯងគត់រហូតដល់សមុទ្រដែលជាព្រំដែនខាងត្បូងនិងអាគ្នេយ៍របស់ប្រទេសនេះ" ។

*៤- ផែនទីមហាអាស៊ីបូព៌ា:*

ផែនទីមហាអាស៊ីបូព៌ា(ដែលសម្គាល់តំបន់សមុទ្រប៉ែកខាងត្បូង) គូរនៅក្នុងសម័យបារាំងរុករានអាស៊ី បានដាក់ព្រំដែនយ៉ាងច្បាស់លាសបំផុត ។ ផែនទីនេះ បានទាំងបង្ហាញយ៉ាងច្បាស់ពីប្រទេសកម្ពុជាដែលលាតសន្ធឹងចាប់ពីព្រំប្រទល់ នៃប្រទេសលាវ រហូតដល់សមុទ្រ(តាមខ្សែទន្លេមេគង្គ) ដោយក្រសោបកម្ពុជាក្រោមទាំងមូលដែលជាផ្នែកទាំងស្រុងមួយ របស់ព្រះរាជាណាចក្រខ្មែរ ។

*៥- ផែនទីឥណ្ឌូចិនរបស់លោក រ៉ូបែរ គូរក្នុងឆ្នាំ១៧១៧:*

ផែនទីមួយទៀតដែលគូរដោយលោក រ៉ូ-បែរត៍(Robert)ក្នុងឆ្នាំ១៧១៧ នៅក្នុងសៀវភៅ "ឥណ្ឌូចិន (Indo-chine)ទំព័រ១១៧ ក្បាលទី១ បានផ្តល់ឯកសារថ្មីមួយទៀតថា កម្ពុជាក្រោមជាដែនដីរបស់ប្រទេសកម្ពុជា ។

*៦- ផែនទីរបស់លោក ឡេ រីវែល ឆ្នាំ១៧៥៥:*

ពេលខាងក្រោយបន្តិចមក គឺមុនសន្ធិសញ្ញាក្រុងវែរសៃ ឆ្នាំ១៧៨៧ ដែលចុះហត្ថលេខារវាងលោក អេវើក ដាដ្រង់ (Eveque d'Adran)ជាតំណាងប្រទេសអណ្ណាម និងប្រទេសបារាំង ហើយដែលតាមសន្ធិសញ្ញានេះ លោក អេវើក

ដាដ្រង់ បាននាំទាហានបារាំងមួយក្រុមចូលមកវាយយកកម្ពុជាក្រោមជាទឹកដីទាំងស្រុងរបស់ប្រទេសកម្ពុជា(សៀវភៅ ឥណ្ឌូចិន... ក្បាលទី១ ទំព័រទី១៣៥ (L'Indochine Tome I, page 135) ។

ផែនទីទាំងនេះ សុទ្ធតែបានបង្ហាញយ៉ាងច្បាស់ថា កម្ពុជាក្រោមជាទឹកដីរបស់ខ្មែរពិតៗ មិនអាចប្រកែកបាន ។ ការ ហូរចូលជនជាតិយួនដំបូងបង្អស់នៅកម្ពុជាក្រោម, តាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាបានសរសេរថា ជនជាតិយួនដែល តាំងទីលំនៅៗលើទឹកដីកម្ពុជាក្រោមដំបូងបង្អស់នៅឆ្នាំ១៦២៣

ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២(១៦១៨-១៦២៥) ដោយព្រះអង្គបានរៀបអភិសេកជាមួយព្រះរាជបុត្រីទី៨របស់ព្រះចៅយួនឈ្មោះកូ ជិន(Co Chin)នៃរាជវង្សNguyên ។ តាមរយៈព្រះរាជអគ្គមហេសីជាជនជាតិយួនដ៏មហិមានៃជនជាតិនេះ គេបានឃើញជនជាតិយួនតាំងទីលំនៅៗលើទឹកដីកម្ពុជាក្រោមលើកដំបូងបង្អស់ចាប់ពីពេលនោះមក ។ ប៉ុន្តែ មិនមែនមានន័យថាព្រះបាទជ័យជេដ្ឋាទី២កាត់ទឹកដីកម្ពុជាក្រោមឱ្យយួនស្របច្បាប់នោះដែរ ។ អន្តោប្រវេសន៍យួនខុសច្បាប់ទាំងនោះ កាន់តែមានចំនួនច្រើនឡើងៗ ព្រមទាំងបានរៀបចំក្បាលម៉ាស៊ីនត្រួតត្រាទឹកដីកម្ពុជាក្រោមជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃ ។

## អំពីការតស៊ូ:

ទោះបីជាជនអន្តោប្រវេសន៍យួនខុសច្បាប់បានតាំងទីលំនៅដ៏ច្រើន និងទន្ទ្រានកាន់កាប់ដីអ្នកភូមិខ្មែរកម្ពុជាក្រោមក៏ ដោយ ក៏ព្រះមហាក្សត្រនិងប្រជារាស្ត្រខ្មែរកម្ពុជាក្រោម មិនដែលបោះបង់ចោលការទាមទារទឹកដីកម្ពុជាក្រោមមកវិញម្តង ណាឡើយ ហើយនៅតែចាត់ទុកថាទឹកដីកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ, ការត្រួតត្រានៃអាណានិគមវៀតណាមនៅលើទឹកដីកម្ពុជាក្រោមជាការខុសច្បាប់ ។ ដូចជានៅក្នុងរជ្ជកាលព្រះបាទអង្គ តូ ឆ្នាំ១៦៤៥, ព្រះបាទអង្គ ច័ន្ទក្នុងឆ្នាំ១៦៥៣ ក៏បាន ធ្វើការទាមទារទឹកដីកម្ពុជាក្រោមមកវិញដែរ ជាពិសេសនៅក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រក៏បានធ្វើការទាមទារយកមកវិញឥតឈប់ឈរ ពិសេសនោះ គឺនៅរាល់សន្និសីទអន្តរជាតិទាក់ទងដល់ ទឹកដីកម្ពុជា ព្រះអង្គតែងតែស្នើសុំរក្សាសិទ្ធិក្នុងការទាមទារទឹកដីកម្ពុជាក្រោមមកវិញជានិច្ច ។ ជាបន្តបន្ទាប់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមបានក្រោកឡើងតស៊ូយ៉ាងស្វិតស្វាញដើម្បីការពារបូរណភាពដែនដី និងពូជសាសន៍ខ្មែរ ទោះបីត្រូវពួកអាណានិគមយួនកាប់សម្លាប់ ធ្វើទារុណកម្មយ៉ាងណាក៏ដោយ ក៏ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមនៅតែតស៊ូការពារពូជសាសន៍ របស់ខ្លួនឱ្យបានគង់វង្សរហូតដល់សព្វថ្ងៃ។ នៅក្នុងផែនការប្រល័យពូជសាសន៍ខ្មែរកម្ពុជាក្រោម អាជ្ញាធរអាណានិគមវៀតណាមបានកាប់សម្លាប់ប្រជារាស្ត្រខ្មែរ និងបំផ្លាញប្រពៃណីវប្បធម៌ អក្សរសាស្ត្រ ភាសាសាស្ត្រខ្មែរយ៉ាងព្រៃផ្សៃបំផុត ។ មិនតែប៉ុណ្ណោះ ពួកអាជ្ញាធរអាណានិគមវៀតណាម បានពុះចែកប្រទេសកម្ពុជាជាពីរ ដោយកេណ្ឌប្រជារាស្ត្រខ្មែររាប់សែននាក់ទៅជីកព្រែកមួយឈ្មោះព្រែក"**វិញតេ**" ចាប់ពីខេត្តពាម(ហាតៀង) រហូតដល់ខេត្តមាត់ជ្រូកក្នុងឆ្នាំ១៨១៥ ។ ព្រែកជីកនេះស្ថិតនៅរហូតដល់បច្ចុប្បន្ន ។ តាមឯកសារបានបញ្ជាក់ថា ពេលប្រជារាស្ត្រខ្មែរកំពុងជីកប្រឡាយនោះ យួនបានលបលួចបង្ហូរទឹកចូលពេញព្រែកធ្វើឱ្យប្រជារាស្ត្រខ្មែរលង់ទឹកស្លាប់រាប់ម៉ឺននាក់ ។

ដោយបានឈ្វេងយល់ឃើញយ៉ាងច្បាស់អំពីឧបាយកលដ៏ខ្មៅងងឹតរបស់យួនក្នុងការលេបត្របាក់យកទឹកដីកម្ពុជា ក្រោមទាំងភ្នែកស្រស់នោះ ព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមាព្រះអង្គឌួង បានផ្ញើព្រះរាជសារជាច្រើនលើកជូនព្រះ ចៅណាប៉ូឡេអុងទីIII ដើម្បីប្រាប់អំពីទឹកដីកម្ពុជាក្រោមថាជាទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា ហើយសូមព្រះចៅណាប៉ូ ឡេអុងទី III

អធិរាជប្រទេសបារាំង កុំទទួលយកអំណោយជា"ទឹកដី"ពីស្តេចអណ្ណាមឱ្យសោះ *ព្រោះទឹកដីកម្ពុជាក្រោមជាទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាទាំងអស់* ។

នៅក្នុងចំណោមព្រះរាជសារទាំងនោះមានឯកសារមួយចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៨៥៦ ជូនអធិរាជ្យ ណាប៉ូឡេអុងទីIII ដោយព្រះអង្គបានឡាយថា: "*ទឹកដីនេះ(កម្ពុជាក្រោម) ត្រូវអណ្ណាមទន្រ្ទានកាន់កាប់ដោយកម្លាំងបាយ ។ តំបន់ដូនណៃត្រូវអណ្ណាមកាន់កាប់ជាង២០០ឆ្នាំមកហើយ ប៉ុន្តែ តំបន់ដែលអាណ្ណាមកាន់កាប់នាពេលថ្មីៗនេះ មានជាអាទិ៍ ទីក្រុង*ព្រៃនគរ, ខេត្តលង់ហោរ, ខេត្តផ្សារដែក, ខេត្តមេស, ខេត្តព្រះត្រពាំង, ខេត្តខ្មុល, ខេត្តបាសាក់, ខេត្តមាត់ជ្រូក, ខេត្តក្រមួនស, ខេត្តទឹកខ្មៅ, ខេត្តពាម, កោះត្រល់, និងកោះត្រឡាច់ ។ល។*ប្រទេសអណ្ណាមត្រូវតែប្រគល់ដែនដីទាំងនេះមកព្រះមហាក្សត្រខ្មែរវិញ ។ ខ្ញុំសូមអង្វរលោក មេត្តាដល់ខ្ញុំ និងប្រជារាស្ត្ររបស់ខ្ញុំ ដើម្បីឱ្យយើងខ្ញុំបានឃើញការបញ្ចប់នៃការបាត់បង់ទឹកដីមាតុភូមិ ជាជាងការស្លាប់នៅក្នុងរាជាណាចក្រដ៏តូចនេះ* " ។

ឆ្នាំ១៨៦៤ ក្នុងពេលដែលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម យាងទៅជួបជាមួយឧត្តមនាវី"ដឺឡាហ្គ្រង់ឌីយ៉ែរ(Aminal de Lagrandiere)នៅទីក្រុងព្រៃនគរ ដោយមានលោក ឌូដា ដឺឡាគ្រេ(Lieutenant Doudart de Lagree)អមព្រះរាជដំណើរផង បានទាមទារយ៉ាងម៉ឺងម៉ាត់បំផុតឱ្យបារាំងប្រគល់ទឹកដីកម្ពុជាក្រោមមកវិញ" ។ ការទាមទារនេះត្រូវបានបារាំងទទួលយកតាមសំណើរបស់ព្រះករុណាព្រះបាទនរោត្តម ។ ដោយសព្វព្រះរាជហឫទ័យនឹងការ ទទួលយកតាមការទាមទារនោះ ព្រះករុណាព្រះបាទ នរោត្តម ក៏ទ្រង់យាងត្រឡប់មកកម្ពុជាវិញនៅខែ តុលា ឆ្នាំ១៨៦៤ ។ តែបារាំងមិនបានគោរពតាមសន្យាទេ ។

នៅឆ្នាំ១៩៤៥ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះរាជនត្តារបស់ព្រះករុណាព្រះបាទអង្គឌួង បាន ផ្ញើចុតហ្មាយមួយច្បាប់ជូនអធិរាជជប៉ុន ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៤៥ ស្តីអំពីសិទ្ធិរបស់ប្រទេសកម្ពុជានៅលើដែនដី កម្ពុជាក្រោម ដោយបានរំឭកឡើងវិញអំពីព្រះរាជសារព្រះករុណាព្រះបាទអង្គ ឌួង ដែលបានផ្ញើជូនអធិរាជ្យណាប៉ូឡេអុង ទី៣ ។ ពិសេសទៀតនោះ ថ្មីៗនេះ ព្រះអង្គទ្រង់មានព្រះរាជបន្ទូលនៅក្នុងព្រះរាជសារមួយច្បាប់ជូនឯកឧត្តមថាច់ សេដ្ឋា សមាជិកព្រឹទ្ធសភា និងជានាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោមចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៣ថា " *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាបន្តបន្ទាប់ និងនរោត្តម សីហនុ មិនដែលប្រគល់ទឹកដីនៃមាតុភូមិកម្ពុជាសូម្បីតែមួយចំអាមជូនទៅវៀតណាម ឬថៃ ឬឡាវនោះទេ ។ នៅក្នុងសម័យណាក៏ដោយ ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសឡាវ មិនដែលមានគុណអ្វីមកលើរាជាណាចក្រកម្ពុជា ហើយមហាក្សត្រខ្មែរ និងនរោត្តម សីហនុ មិនដែលក្បត់ជាតិ ប្រជារាស្ត្រ មាតុភូមិកម្ពុជាម្តងណាឡើយ*" ។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៥ ព្រះករុណាព្រះមហាវីរក្សត្រ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ មានព្រះរាជបន្ទូលយ៉ាងច្បាស់អំពីអាណានិគមបារាំងកាត់ទឹកដីកម្ពុជាក្រោមឱ្យទៅអាណានិគមវៀតណាមនៅឆ្នាំ ១៩៤៩នោះ ថាជាការខុសច្បាប់និងអយុត្តិធម៌បំផុត ។ យ៉ាងហោចណាស់ ក៏បារាំងត្រូវប្រគល់ទឹកដីកម្ពុជាក្រោម៥០%មកឱ្យព្រះរាជាណាចក្រកម្ពុជាដែរ ។

ប៉ុន្តែគួរឱ្យសោកស្តាយ ក្នុងពេលដែលប្រជារាស្ត្រខ្មែរក្រោកឡើងតស៊ូទាមទារទឹកដីកម្ពុជាក្រោមមកវិញនោះស្រាប់តែបារាំងប្រកាសទទួលស្គាល់ឯករាជ្យរបស់ប្រទេសវៀតណាម ហើយបានលើកបន្ទុបស្តេច**បាវ ដាយ** ឱ្យគ្រងរាជ្យនៅថ្ងៃទី៨ មីនា ឆ្នាំ១៩៤៩ ដើម្បីទប់ទល់នឹងសកម្មភាពរបស់ពួកកុម្មុយនីស្តហូ **ជីមិញ** ។ មួយខែក្រោយមក ដោយសារចង់លើកទឹកចិត្តស្តេច**បាវ ដាយ**ឱ្យជួយការពារអំណាចអាណានិគមរបស់ខ្លួនប្រឆាំងកុម្មុយនីស្តហូ **ជីមិញ**នោះ បារាំងបានប្រកាសប្រគល់ទឹកដីកម្ពុជាក្រោមឱ្យស្តេច**បាវ ដាយ**នៅខែ មេសា ១៩៤៩ ។ ប៉ុន្តែ ការប្រកាសរបស់បារាំងនេះមិនទាន់សម្រេចជាផ្លូវការទេ គឺត្រូវនៅរង់ចាំការអនុម័តពីសភាបារាំងសិន។

ដំណឹងនេះ បានធ្វើឱ្យថ្នាក់ដឹកនាំនៃប្រទេសកម្ពុជាភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៤៩ ព្រះមហាក្សត្រខ្មែរបានបញ្ជូនប្រតិភូរាជរដ្ឋាភិបាលមួយក្រុម ដឹកនាំដោយឯកឧត្តម**ឈាន វ៉ម** នាយករដ្ឋមន្ត្រីមកពីគណបក្សប្រជាធិបតេយ្យអញ្ជើញទៅទីក្រុងបារីសប្រទេសបារាំង ដើម្បីតវ៉ានឹងព្រឹទ្ធសភាបារាំងឱ្យផ្អាកការសម្រេចចិត្តរបស់រដ្ឋាភិបាល និងរដ្ឋសភាបារាំងដែលបានយល់ព្រមប្រគល់ទឹកដីកម្ពុជាក្រោមឱ្យវៀតណាមនោះសិន ។ ប៉ុន្តែ ដោយសារជំពាក់វ៉ាក់វិននឹងអាជ្ញាធរអាណានិគមវៀតណាមមិនអាចដោះដៃបាន ទើបព្រឹទ្ធសភាបារាំងក៏បានអនុម័តច្បាប់ប្រគល់ទឹកដីកម្ពុជាក្រោម(ដែលបារាំងហៅថាកូសាំងស៊ីន) ឱ្យទៅអាជ្ញាធរអាណានិគមវៀតណាមនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩តែម្តង ។ ច្បាប់បារាំងដែលកាត់ទឹកដីកម្ពុជាក្រោមឱ្យអាជ្ញាធរអាណានិគមវៀតណាម មានសេចក្តី(ភាសាបារាំង)ទាំងស្រុងថា:

Loi N° 49-733 du 4 Juin 1949 modifiant le statut de la Cochinchine dans l'Union française.

Après avis de l'Assemblée nationale de l'Union française,

L'Assemblée nationale et le Conseil de la République ont délibéré,

L'Assemblée nationale a adopté,

Le Président de la République promulgue la loi dont la teneur suit:

Art. 1$^{er}$ – Dans le cadre fixé à L'article 60 le la Constitution de la République française et après l'avis émis, dans sa séance du 23 Avril 1949, par l'Assemblée territoriale de Cochinchine, le statut de la Cochinchine est modifié dans les conditions prévues à l'article ci-après.

Art. 2. – Le territoire de la Cochinchine est rattaché à l'Etat associé du Viet-Nam suivant les termes de la déclaration commune du 5 juin 1948 et de la déclaration du Gouvernement français du 19 aoùt 1948.

La Cochinchine cesse en conséquence d'avoir le statut de territoire d'outre-mer.

Art. 3 – En cas de changement du statut du Viet-Nam, le statut de la Cochinchine fera l'objet d'une nouvelle délibération des assemblées prévues à l'article 75 de la Constitution (Titre VIII: De l'Union française).

La présente loi sera execute comme loi de l'Etat.
Fait à Toulon, le 4 Juin 1949.

VINCENT AURIOL
*1er le Président de la République:*

*Le président du conseil des ministres,*
HENRI QUEUILLE.

*Le Ministère de la France d'outre-mer,*
PAUL COSTE-FLORET.

ប្រែជាភាសាខ្មែរ( ក្រៅផ្លូវការ) ថា:

*ច្បាប់លេខ៤៩-៧៣៣ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩*

*យោងមតិពីរដ្ឋសភានៃសហភាពបារាំង*

*រដ្ឋសភា និងក្រុមប្រឹក្សានៃសាធារណរដ្ឋបារាំង បានសម្រេច*

*រដ្ឋសភានៃសាធារណរដ្ឋបារាំង បានអនុម័ត*

*ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ប្រកាសច្បាប់ដូចតទៅនេះ:*

*មាត្រា១-ក្នុងក្របខណ្ឌមាត្រា៦០នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំង និងតាមមតិរបស់សភាកូសាំងស៊ីននាសម័យប្រជុំថ្ងៃទី២៣ មេសា ១៩៤៩ លក្ខន្តិកៈទឹកដីកូសាំងស៊ីនបានត្រូវកែប្រែតាមមាត្រាដូចមានចែងខាងក្រោម ។*

*មាត្រា២-ទឹកដីកូសាំងស៊ីនត្រូវបានភ្ជាប់ទៅជារដ្ឋចំណុះវៀតណាម យោងតាមសេចក្តីប្រកាសរួមកាលពីថ្ងៃទី៥ ខែ*

*មិថុនា ឆ្នាំ១៩៤៨ និងសេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំង កាលពីថ្ងៃទី១៩ សីហា ១៩៤៨ ។*

*ទឹកដីកូសាំងស៊ីន ឈប់ស្ថិតនៅក្នុងលក្ខន្តិកៈជាទឹកដីឯនាយសមុទ្ររបស់បារាំងទៀតហើយ ។*

*មាត្រា៣-ក្នុងករណីដែលលក្ខន្តិកៈប្រទេសវៀតណាមត្រូវកែប្រែ*

*លក្ខន្តិកៈកូសាំងស៊ីននឹងត្រូវទុកជាកម្មវត្ថុនៃការ*

*សម្រេចរបស់សភាខាងលើ ដូចមានចែងក្នុងមាត្រា៧៥នៃរដ្ឋធម្មនុញ្ញ( ជំពូក VIII: សហភាពបារាំង) ។*

*ច្បាប់នេះ នឹងត្រូវបានអនុវត្តដូចជាច្បាប់រដ្ឋ ។*

*ធ្វើនៅទូឡុង ថ្ងៃទី០៤ មិថុនា ឆ្នាំ១៩៤៩*

| | | |
|---|---|---|
| *ហត្ថលេខា* | *ហត្ថលេខា* | *ហត្ថលេខា* |
| | | |
| ***វ៉ាំងសង់ អុរីយ៉ូល*** | ***ហង់រី កឹយ*** | ***ប៉ូល កូស្ត-ផ្លរ៉េត៏*** |
| *ប្រធានាធិបតី* | *នាយករដ្ឋមន្ត្រី* | *រដ្ឋមន្ត្រីទឹកដីបារាំងឯនាយសមុទ្រ* |

ដើម្បីបង្ហាញអំពីការប្រឆាំងច្បាប់ទុរយសនេះជាបន្តទៀត កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៣ សហគមន៍ខ្មែរកម្ពុជាក្រោមបានជូនញត្តិមួយច្បាប់ទៅរដ្ឋសភានិងព្រឹទ្ធសភាបារាំងស្នើសុំឱ្យធ្វើច្បាប់ថ្មីលុបច្បាប់លេខ៤៩-

៧៣៣នេះចេញ ព្រោះជាច្បាប់ដ៏អយុត្តិធម៌និងគ្រោះថ្នាក់បំផុតដល់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ។ ញត្តិនេះសហគមន៍ខ្មែរកម្ពុជាក្រោម ក៏បានស្នើសុំការគាំទ្រនិងអន្តរាគមន៍ពីព្រះមហាក្សត្រ រដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលខ្មែរដែរ ។ ប៉ុន្តែ គួរឱ្យសោក ស្តាយ មានតែព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាតែមួយព្រះអង្គគត់ ដែលបានគាំទ្រ ។ រីឯរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលពុំបានផ្តល់ចម្លើយអ្វីទាំងអស់ ។ ដើម្បីបង្ហាញឱ្យឃើញច្បាស់អំពីការប្រឆាំងយ៉ាងដាច់ខាតទៅលើច្បាប់កាត់ទឹកដីខ្មែរទៅឱ្យអាណានិគមវៀតណាមនោះ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០០៥នេះ ព្រះករុណាព្រះមហាវីរក្សត្រព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ** បានព្រះរាជលិខិតនៅក្នុងព្រះរាជសារមួយច្បាប់ថា "*ការកាត់ទឹកដីខ្មែរកម្ពុជាក្រោមទៅឱ្យអាណានិគមវៀតណាមនៅឆ្នាំ១៩៤៩នោះ គឺជាការខុសច្បាប់និង អយុត្តិធម៌បំផុត យ៉ាងហោចណាស់ក៏បារាំងត្រូវប្រគល់ទឹកដីកម្ពុជាក្រោម៥០%មកឱ្យព្រះរាជាណាចក្រកម្ពុជាដែរ*" ។

គួររំឭកថា នៅក្នុងសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ស្តីពីឥណ្ឌូចិន ឯកឧត្តមទេព ផន ជាព្រះរាជប្រតិភូនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងសុន្ទរកថានៅក្នុងសន្និសីទនោះ និងធ្វើសារណាមួយដើម្បីរក្សាសិទ្ធិជាប្រវត្តិសាស្ត្ររបស់កម្ពុជានៅលើទឹកដីកម្ពុជាក្រោម ដោយបានបញ្ជាក់បន្ថែមអំពីភស្តុតាងនានាដែលបង្ហាញថាកម្ពុជាក្រោម(កូសាំងស៊ីន)ជាទឹកដីរបស់ខ្មែរ ។

នៅក្នុងសារណារបស់ឯកឧត្តមទេព ផន បានសរសេរថា"ក្នុងវិស័យបុរាណវត្ថុវិទ្យា ប្រាង្គប្រាសាទ បដិមា ធ្វើពីសំរិត ពីថ្ម វត្តអារាមព្រះពុទ្ធសាសនា បដិសណ្ឋានធ្វើអំពីឥដ្ឋ និងសិលាចារិកនានា បានបញ្ជាក់យ៉ាងច្បាស់អំពីវត្តមានខ្មែរ តាំងពីដូនតាមកនៅក្នុងតំបន់នេះ ។

ឆ្នាំ១៨២១ លោកឧកញ៉ា**សឺន គុយ** បានបូជាជីវិតដោយអាជ្ញាធរវៀតណាមកាត់កទាំងរស់ ដើម្បីជាថ្នូរកុំឱ្យយួនរំលាយព្រះពុទ្ធសាសនា និងពូជសាសន៍ខ្មែរ ព្រោះនៅពេលនោះ យួនបានសម្លាប់ប្រជារាស្ត្រខ្មែរទាំងភូមិៗ ជាន់ឈ្លីព្រះពុទ្ធ សាសនានិងទំនៀមទម្លាប់វប្បធម៌ខ្មែរយ៉ាងឃោរឃៅបំផុត ។ ឆ្នាំ១៩៤៥ យួនបានកេណ្ឌប្រជារាស្ត្រខ្មែររាប់សែននាក់ចូល ទៅក្នុងជង្រុកស្រូវនៅខេត្ត**ទឹកខ្មៅ** និងខេត្ត**ពលលាវ** រួចចាក់សាំងដុតសម្លាប់ទាំងរស់ ។ ឆ្នាំ១៩៧៦ យួនបានបង្ក្រាបការបះបោរទាមទារសិទ្ធិសេរីភាពរបស់ខ្មែរកម្ពុជាក្រោមយ៉ាងសាហាវរកទីបំផុតគ្មាន ដោយបាញ់សម្លាប់ និងចាប់ធ្វើទារុណ កម្មយ៉ាងឃោរឃៅព្រៃផ្សៃ ដូចជាយួនបានកាត់ទោសប្រហារជីវិតប្រជារាស្ត្រខ្មែរ៣នាក់ដែលយួនចោទប្រកាន់ថា ជាមេ ដឹកនាំបះបោរគឺលោក**ថាច់ គិន** លោក **ថាច់ ឌាក** និងលោក**គឹម រី** ។ ឆ្នាំ១៩៨៥-១៩៨៧ អាជ្ញាធរអាណានិគមវៀតណាម បានបើកយុទ្ធនាការប្រល័យពូជសាសន៍ខ្មែរសាជាថ្មី ដោយបិទសាលារៀនភាសាខ្មែរ ចាប់អ្នកប្រាជ្ញបញ្ញវន្តខ្មែរ យកទៅដាក់ពន្ធនាគារ ធ្វើទារុណកម្មនិងសម្លាប់រាប់ម៉ឺននាក់ ។ នៅក្នុងយុទ្ធនាការនេះ អាជ្ញាធរអាណានិគមវៀត ណាមបានចាប់ព្រះសង្ឃនិងប្រជារាស្ត្រខ្មែរចំនួន៤.២៤៨នាក់ ធ្វើទារុណកម្ម និងដាក់ពន្ធនាគារ ហើយរាប់រយនាក់ផ្សេង ទៀតត្រូវអាជ្ញាធរសម្លាប់ ក្នុងនោះមានព្រះតេជគុណកន្តធម្មោ**គឹម តុកចើង**ព្រះមេគណខេត្តព្រះត្រពាំង និងជាសង្ឃនាយក ខ្មែរកម្ពុជាក្រោមដែលបានបំផុសចលនាព្រះសង្ឃ

និងប្រជារាស្ត្រខ្មែរឱ្យសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរ ដោយត្រូវអាជ្ញាធរយួនចាប់ផ្សឹកដាក់ពន្ធនាគាររួចចាក់ថ្នាំសម្លាប់នៅឆ្នាំ១៩៨៧ និងលោកបណ្ឌិតាចារ្យហាញ់ សុវណ្ណ នាយកពុទ្ធិកសិក្សា នៅកម្ពុជាក្រោម ត្រូវអាជ្ញាធរអាណានិគមយួនចាប់ធ្វើទារុណយ៉ាងវេទនា និងបង្អត់អាហារឱ្យស្លាប់នៅក្នុងពន្ធនាគារ ឆ្នាំ ១៩៨៧ ជាដើម ។

## អំពីសហគមន៍ខ្មែរកម្ពុជាក្រោម:

ស្របពេលជាមួយនឹងមនុស្សជាតិនៅលើពិភពលោកទាំងមូលប្រារព្ធពិធីអបអរសាទរសហស្សវត្សរ៍ថ្មីឆ្នាំ២០០០ ប្រជារាស្ត្រខ្មែរកំណើតកម្ពុជាក្រោមនៅជុំវិញពិភពលោក បានមកជួបជុំគ្នាប្រារព្ធពិធីអបអរសាទរសហស្សវត្សរ៍ថ្មីនៅសាល សន្និសីទចតុមុខ រាជធានីភ្នំពេញ ដូចមនុស្សជាតិនានានៅលើសកលលោកដែរ ។ ដើម្បីបង្ហាញពិភពលោកឱ្យបានដឹងថា ពិធី អបអរសាទរសហស្សវត្សរ៍ថ្មីរបស់ជនរួមជាតិខ្មែរកម្ពុជាក្រោមនេះ ជាកាបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀតនៃការចាប់ ផ្តើមបន្តការតស៊ូដើម្បីសិទ្ធិសេរីភាពរបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម តាមមាគ៌ាអហិង្សានៃច្បាប់ជាតិ និងអន្តរជាតិ ហើយក៏ជាការបញ្ជាក់ប្រាប់ពិភពលោកឱ្យបានដឹងផងដែរថា រហូតមកដល់ឆ្នាំ២០០០នេះ នៅកម្ពុជាក្រោម(វៀតណាម ខាងត្បូង)មានប្រជារាស្ត្រខ្មែរជាង១២លាននាក់ កំពុងរស់នៅយ៉ាងវេទនាជាទីបំផុត ប៉ុន្តែមិនទាន់បាត់ពូជសាសន៍ ឬអត្ត- សញ្ញាណជាខ្មែរនៅឡើយ ។

នៅក្នុងពិធីអបអរសាទរសហស្សវត្សរ៍ថ្មីនេះ មានប្រជារាស្ត្រខ្មែរទាំងព្រះសង្ឃទាំងគ្រហស្ថចូលរួមប្រមាណជាង ១.៥០០រូប ជាតំណាងឱ្យប្រជារាស្ត្រខ្មែរជាង១២លាននាក់ ដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោម ក្រោមអធិបតីភាព ឯកឧត្តមគង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា(**ដាក់រូបថត**) ។ ក្នុងពេលជាមួយគ្នានោះ ឯកឧត្តម ថាច់ សេដ្ឋាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលជាប្រធានគណ:កម្មការរៀបចំបុណ្យបានប្រកាសបង្កើតជា ផ្លូវការនូវ "មូលនិធិខ្មែរកម្ពុជាក្រោម " ដែលមានឯកឧត្តមផ្ទាល់ជាប្រធាន ។

ក្រោយពីដំណើរការបានរយៈពេលពីរឆ្នាំ, ដោយមានការផ្តល់យោបល់ពីអង្គការ-សមាគមខ្មែរកម្ពុជាក្រោមទាំង ១០នៅព្រះរាជាណាចក្រកម្ពុជា មូលនិធិខ្មែរកម្ពុជាក្រោមក៏បានប្តូរមកជា *"សហគមន៍ខ្មែរកម្ពុជាក្រោម"* ដើម្បីឱ្យក្លាយទៅ ជាអង្គការចាត់តាំងតស៊ូមតិតាមច្បាប់ជាតិ និងអន្តរជាតិ ទាមទារសិទ្ធិសេរីភាពជូនប្រជារាស្ត្រខ្មែរកម្ពុជាក្រោមស្រមតាម ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយ ដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារដែលមនុស្សទូទៅត្រូវតែមាន ។

សហគមន៍ខ្មែរកម្ពុជាក្រោម មានចរិតលក្ខណ:ជាអង្គការអព្យាក្រិត ក្រៅរដ្ឋាភិបាល និងមិនមាននិន្នាការទៅរកគណបក្សនយោបាយ ដែលជាអង្គការការពារឧត្តមប្រយោជន៍សហគមន៍ខ្មែរកម្ពុជាក្រោមទាំងមូលក្នុងគោលបំណង:

១- ធ្វើការតស៊ូទាមទារសិទ្ធិសេរីភាពជូនប្រជារាស្ត្រខ្មែរកម្ពុជាក្រោមដោយអហិង្សាតាមច្បាប់ជាតិ-អន្តរជាតិ ។

២- ស្រាវជ្រាវ និងបោះពុម្ពផ្សាយវប្បធម៌ និងទឹកដីខ្មែរកម្ពុជាក្រោមក្នុងន័យដើម្បីថែរក្សា ការពារសិល្បៈ វប្បធម៌ អក្សរសាស្ត្រ ភាសាសាស្ត្រ ប្រពៃណី ទំនៀមទំលាប់ខ្មែរកម្ពុជាក្រោម ។

៣- បណ្តុះបណ្តាលធនធានមនុស្ស ។

សហគមន៍ខ្មែរកម្ពុជាក្រោម ត្រូវបានក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់នៅថ្ងៃទី២៥ ខែមិនា ឆ្នាំ
២០០៣ និងទទួលបានការគាំទ្រនិងអបអរសាទរយ៉ាងពេញទំហឹងពីព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា តាមព្រះរាជសារចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ ។

**ព្រះករុណាព្រះបាទសម្តេចព្រះ**

**នរោត្តម សីហនុ**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

ជូន: ឯកឧត្តម **ថាច់ សេដ្ឋា**

សមាជិកព្រឹទ្ធសភា

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

ឯកឧត្តមជាទីរាប់អាន និងស្រឡាញ់ដ៏ជ្រាលជ្រៅ

ខ្ញុំបានទទួលរួចហើយលិខិតចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣ ព្រមទាំងឯកសារមួយចំនួនរបស់ឯកឧត្តម ។

ខ្ញុំសូមអរគុណដ៏ជ្រាលជ្រៅចំពោះដំណឹងខាងលើនេះ ព្រមទាំងសូមសរសើរដ៏កក់ក្តៅការរួបរួមគ្នាជាសមាគមខ្មែរ កម្ពុជាក្រោមចំនួនទាំង១០ ដើម្បីបង្កើតឡើងនូវសហគមន៍ខ្មែរកម្ពុជាក្រោម ដែលមានភារកិច្ចគិតគូរអំពីសុខទុក្ខរបស់កូន ចៅខ្មែរកម្ពុជាក្រោម ។

ខ្ញុំសូមជូនពរឯកឧត្តម និងសហគមន៍ខ្មែរកម្ពុជាក្រោម ទទួលបានជោគជ័យក្នុងការបំពេញភារកិច្ចបេសកកម្មបំរើ ឧត្តមប្រយោជន៍នៃកូនចៅខ្មែរកម្ពុជាក្រោម ព្រមទាំងបានប្រកបតែនឹងពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តម ទទួលនូវសេចក្តីរាប់អាន និងស្រឡាញ់ដ៏ជ្រាលជ្រៅ អំពីខ្ញុំ និងសម្តេចព្រះរាជអគ្គមហេសី ។

**នរោត្តម សីហនុ**

ប៉ៃកាំង ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣

## អំពីបេសកកម្មរបស់សហគមន៍ខ្មែរកម្ពុជាក្រោម:

ស្ថិតនៅក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ឯកឧត្តមថាច់ សេដ្ឋា សមាជិកព្រឹទ្ធសភា និងជានាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម រួមជាមួយសហការីដ៏សំខាន់ៗ និងដោយមានការសហការល្អជាមួយអង្គការ-សមាគមខ្មែរកម្ពុជាក្រោមទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា សហគមន៍ខ្មែរកម្ពុជាក្រោមទទួលបានការគាំទ្រយ៉ាងខ្លាំងក្លាពីសហគមន៍ ជាតិ និងអន្តរជាតិ ។

ផ្តើមចេញពីការសាមគ្គីដ៏ស្អិតរមួតនៃប្រជាជាតិខ្មែរកំណើតកម្ពុជាក្រោម សហគមន៍ខ្មែរកម្ពុជាក្រោម បានធ្វើសកម្មភាពបម្រើឧត្តមប្រយោជន៍ប្រជាជាតិខ្មែរកម្ពុជាក្រោម ប្រកបដោយជោគជ័យ ហើយពីមួយឆ្នាំទៅមួយឆ្នាំមានការ រីកចម្រើនគួរឱ្យកត់សម្គាល់ ។

សកម្មភាពលេចធ្លោទាំងនោះរួមមាន:

- ការប្រារព្ធពិធីបុណ្យអបអរសាទរសហស្សវត្សរ៍ថ្មីនៅសាលសន្និសីទចតុមុខថ្ងៃទី១ ខែមករា ឆ្នាំ២000 ។
- ការប្រកាសយកថ្ងៃ0៤ ខែមិថុនា ជាទិវាកាន់ទុក្ខរបស់ជាតិខ្មែរកម្ពុជាក្រោម គឺថ្ងៃអាណានិគមបារាំងកាត់ទឹកដីកម្ពុជាក្រោមប្រគល់ឱ្យអាជ្ញាធរអាណានិគមវៀតណាម ហើយក៏ជាការកំណត់ថ្ងៃធ្វើបុណ្យរាប់បាត្រព្រះសង្ឃចំនួន១.៩៤៩អង្គ ដើម្បីឧទ្ទិសកុសលប្រគេន ថ្វាយ និងជូនវិញ្ញាណក្ខន្ធ និងព្រះវិញ្ញាណក្ខន្ធបុព្វបុរស ខ្មែរស្នេហាជាតិផងដែរ ។ ពិធីនេះ មានការនិមន្ត និងអញ្ជើញចូលរួមពីសំណាក់ព្រះសង្ឃ និងពុទ្ធបរិស័ទពី ៥.000នាក់ ទៅ៦.000នាក់ជារៀងរាល់ឆ្នាំ ។
- បានផ្តួចផ្តើមប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ២ធ្នូ ដោយឡែករបស់ខ្មែរកម្ពុជាក្រោមចាប់ពីឆ្នាំ២000រហូតមកដល់សព្វថ្ងៃ ។
- ធ្វើសិក្ខាសាលាស្តីពីសិទ្ធិជនជាតិដើម
- ចុះអន្តរាគមន៍រាល់ការរំលោភសិទ្ធិមកលើជនរួមឈាមខ្មែរកម្ពុជាក្រោម
- ធ្វើសេចក្តីថ្លែងការណ៍ សន្និសីទសារពត៌មាន ធ្វើបទសម្ភាសន៍និងកម្មវិធីតុមូលស្តីពីបញ្ហាខ្មែរកម្ពុជាក្រោមចាក់ផ្សាយតាមវិទ្យុជាដើម ។
- ធ្វើញត្តិផ្តិតមេដៃថ្កោលទោសមេដឹកនាំយួន
- សរសេរលិខិតជូនរដ្ឋសភា ព្រឹទ្ធសភា និងរដ្ឋាភិបាលបារាំង សុំឱ្យលុបច្បាប់លេខ៤៩-៧៣៣ ។
- សរសេរលិខិតជូនមេដឹកនាំព្រះពុទ្ធសាសនានៅលើពិភពលោកស្តីពីការរំលោភសិទ្ធិព្រះពុទ្ធសាសនានៅកម្ពុជាក្រោម ។
- សរសេរលិខិតជូនរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកស្តីពីស្ថានភាពរំលោភសិទ្ធិមនុស្សមកលើខ្មែរកម្ពុជាក្រោម ។
- ចូលជាសមាជិក Transnational Radical Party

- ប្រជុំជាមួយក្រុមអ្នកច្បាប់រាជរដ្ឋាភិបាលនៅទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីសំណើទាំង៥ចំណុចរបស់សហគមន៍ខ្មែរកម្ពុជាក្រោម ។
- ជួបប្រជុំជាមួយវិជ្ជាស្ថានសាធារណរដ្ឋអន្តរជាតិ(IRI) អំពីគម្រោងជំនួយដល់សហគមន៍ខ្មែរកម្ពុជាក្រោម
- ជួបប្រជុំជាមួយស្នងការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ(UNHCR) ស្តីពីទុក្ខ លំបាករបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម និងការភៀសខ្លួនរបស់ខ្មែរកម្ពុជាក្រោមមកប្រទេសកម្ពុជា ។

Website of Khmer Kampuchea Krom Community: [www.khmerkromngo.org](http://www.khmerkromngo.org)